Hillside Terrace
Tacoma Housing Authority

# ព្រឹត្តប័ត្រនៃការធ្វើឲ្យមានជីវិតថ្មីនៅតំបន់ Hillside Terrace

ខ្សែទី 2
ខែតុលា ឆ្នាំ 2009

## តើមានអ្វីកើតឡើងនៅពេលនេះ?

ខែកញ្ញាគឺជាខែមមារញឹកបំផុតនៅតំបន់ Hillside Terrace ប្លុក 1800 និង 2500, ដោយសហគមន៍ មានមុខងារយ៉ាងសកម្មនៅក្នុងដំណើរការនៃការធ្វើឲ្យមានជីវិតថ្មីឡើងវិញ។

- នៅថ្ងៃទី 8 ខែកញ្ញា, និវេសកជននៅតំបន់ Hillside Terrace បានជួបជាមួយនឹងបុគ្គលិកនៃអាជាធរក្រុងតាខូម៉ា ដើម្បីចែករំលែកពីគំនិតអំពីការគាំទ្រនៃសេវានានា ដែលត្រូវបានផ្តល់នៅឱកាសពេលកំពុងសាងសង់ និងក្រោយពេលសាងសង់។
- នៅថ្ងៃទី 15 ខែកញ្ញា, និវេសកជននិងសមាជិកនៃសហគមន៍ • បានចូលរួមក្នុងសិក្ខាសាលាមួយ ដែលបានផ្តោតទៅលើប្លង់អាគារលំនៅដ្ឋានរបស់បុគ្គលម្នាក់ៗនិងផែនការកន្លែងការដ្ឋាន។
- នៅថ្ងៃទី 22 ខែកញ្ញា, បុគ្គលិករបស់THA, ក្រុមអ្នកធ្វើប្លង់, និង និវេ សកជន • អ្នកតំណាងនានាបានចូលរួមនៅក្នុងសិក្ខាសាលាចំនួនកន្លះថ្ងៃ ដើម្បីអភិវឌ្ឍន៍នូវគំនិតនានាសំរាប់ប្រើប្រាស់ថាមពលនិងធនធានទាំងអស់ឲ្យមានប្រសិទ្ធិភាពនៅអាគារតំបន់ Hillside Terrace ថ្មី។
- និវេសកជនបានត្រឡប់ទៅវិញនៅថ្ងៃទី 29 ខែកញ្ញា ដើម្បីសួរនូវសំណួរនានា • អំពីការផ្លាស់ប្តូរកន្លែង នៅមុនពេលការសាងសង់និងការត្រឡប់ទៅវិញនៅក្រោយពេលការសាងសង់។
- ដោយបន្ថែមទៀត, THA ត្រូវមានការមមារញឹកក្នុងការរៀបចំក្រដាសពាក្យសុំជំនួយពីកម្មវិធី• HUD HOPE VI ដើម្បីជួយផ្តល់ប្រាក់ជំនួយដល់គំរោងការធ្វើឲ្យមានជីវិតថ្មីឡើងវិញ ដែលនឹងត្រូវដាក់សុំនៅពេលពាក់កណ្តាលខែវិច្ឆិកា។

យើងមានអារម្មណ៍យ៉ាងរំភើប ក្នុងការមានសមាជិករបស់សហគមន៍នៅតំបន់Hillside Terrace មកចូលរួមយ៉ាងច្រើននៅក្នុងដំណើរការផែនការនិងប្លង់នេះ។ ការបន្តការចូលរួមរបស់លោកអ្នកបានធ្វើឲ្យមានការប្រាកដថា តំបន់ Hillside Terrace ថ្មីនឹងទៅជាកន្លែងមួយ ដែលជួបនូវសេចក្តីត្រូវការរបស់សហគមន៍ និងបញ្ឆាំងតបទៅនឹងតំលៃរបស់សហគមន៍។

អត្ថបទនៅក្នុងព្រឹត្តប័ត្រនេះគឺការសរុបនៃសិក្ខាកម្មលើប្លង់របស់សហគមន៍នៅថ្ងៃទី 15 ខែកញ្ញា ហើយនិងពិនិត្យឡើងវិញនៃប្លង់ដើមនៃការធ្វើឲ្យមានជីវិតថ្មីឡើងវិញនៅតំបន់ Hillside Terrace ។



## សូមចូលរួមជាមួយយើងនៅពេលប្រជុំសហគមន៍លើកក្រោយ!

ពិភាក្សាអំពីទស្សនៈនៃប្លង់ដើម ជាមួយនឹងអ្នកស្ថាបត្យករនិងបុគ្គលិកនៃ THA ។

ថ្ងៃព្រហស្បតិ៍ ទី 29 ខែតុលា ឆ្នាំ 2009
ម៉ោង 5:00 ល្ងាចដល់ម៉ោង 7:30 យប់ – មានផ្តល់ជូនភេសជ្ជៈ
នៅ Goodwill Industries
Milgard Work Opportunity Center
714 South 27th Street
Multi-Purpose Room 338
Tacoma

កុមារទាំងអស់យើងទទួលស្វាគមន៍ — កន្លែងក្មេងលេងកំសាន្តនឹងមានផ្តល់ជូន។



# ប្លង់របស់សមាជិកសហគមន៍នៃតំបន់ Hillside Terrace

នៅថ្ងៃទី 15 ខែកញ្ញា, អាជាធរលំនៅដ្ឋានក្រុងតាខូម៉ាបានទទួលធ្វើសិក្ខាសាលាអំពីប្លង់លើកទីពីរសំរាប់ប្លុក 1800 និងប្លុក 2500 នៃការធ្វើឲ្យមានជីវិតថ្មីឡើងវិញនៃតំបន់ Hillside Terrace ។ និវេសកជនលើសពី 40 នាក់ និងអ្នកចូលរួមចំណែកក្នុងសហគមន៍បានធ្វើការទន្ទឹមគ្នានឹងក្រុមអ្នកធ្វើប្លង់ ដើម្បីធ្វើសំណើរនូវ គំនិតនានាសំរាប់ធ្វើប្លង់នៅក្នុងអាគារ ហើយនិងថាតើអាគារអាចត្រូវលាតសន្ធឹងរបៀបណានៅលើការដ្ឋាន។

ការប្រជុំនៅពេលល្ងាចបានចាប់ផ្តើមដោយមានអាហារពេលល្ងាចទទួលទាន និងការបើកឲ្យទស្សនា ដែលនៅពេលនោះអ្នកចូលរួមទាំងអស់បានសួរសំណួរនានាដល់ក្រុមអ្នកធ្វើប្លង់របស់ THA ។ នៅពេលនោះ អ្នកចូលរួមទាំងអស់បានចែកជាក្រុមធ្វើការតូចៗ ហើយនិងបានពិភាក្សាលើផ្នែកអាគារលំនៅដ្ឋានមួយៗ នៅតំបន់ Hillside Terrace ថ្មី, ដោយរួមទាំងជំរើសផែនការចំនួនជាន់នៃអាគារ និងជំរើសចុងក្រោយ ដូចជា ពណ៌ថ្នាំនិងការដាក់កំរាលជាដើម។ ក្រុមអ្នកធ្វើការក៏បានពិភាក្សាអំពីទីធ្លាសហគមន៍នៅតំបន់ Hillside Terrace ថ្មី និងពីរបៀបសហការគាំទ្រសំខាន់ៗ ហើយនិងការអនុវត្តន៏នៃកន្លែងគេហដ្ឋាន និងកន្លែងទូទៅនានា។ ក្រុមនិមួយៗបានលើកទឹកចិត្តឲ្យចូលរួមក្នុងកន្លែងដែលពួកគេបានដាក់សំណើរលើ ផែនការការដ្ឋានប្លុក 1800 និង 2500។



## សេវាសហគមន៍ និងសេវាគាំទ្រ

THA កំពុងធ្វើការជាមួយគូភាគីសហគមន៍ទាំងអស់ដើម្បីផ្តល់ជូននូវកម្មវិធីសេវាផ្សេងៗខុសៗគ្នា ដើម្បីគាំទ្រនិវេសកជននៃតំបន់ Hillside Terrace ថ្មី។ កម្មវិធីទាំងអស់មានរួមទាំង:

សំរាប់យុវ:ជន: កម្មវិធីថ្នាក់មតេយ្យដ្ឋាន, កម្មវិធីនៅពេលចេញពីរៀន, ការណែនាំ, និងកម្មវិធីសិក្សា ទូទៅនៅរដូវក្តៅ និងបង្រៀនសិស្សមួយទល់មួយ។

សំរាប់យុវជននៅក្មេង:ការអភិវឌ្ឍន៍ឋាមពលពលកម្ម, កម្មវិធីសិក្សា, និងធ្វើការហ្វឹកហ្វឺននៃការអាន។

សំរាប់មនុស្សធំ: ថ្នាក់ផ្នែកមាតាបិតា,ថ្នាក់ជំនាញការងារ, ថ្នាក់GED, សេវាសំរាប់មនុស្សចាស់ និងនិវេសកជនពិការ និងគ្រួសារអន្តោប្រវេសន៍, ថ្នាក់ការចូលសញ្ជាតិ, ថ្នាក់ភាសាអង់គ្លេសជាភាសាទីពីរ, និងថ្នាក់សេវាគ្រប់គ្រងសំណុំរឿង។

## អ្វីដែលយើងបានឮ:

### ផែនការចំនួនជាន់អាគារ និងជំរើសចុងបញ្ចប់

- ដាក់ចង្ក្រានដាំស្លនៅផ្នែកខាងក្រោយផ្ទះ
- រៀបចំអាគារ ឲ្យមានអារម្មណ៏ថាធំនិងមានភាពឯកជន
- ចំណូលចិត្តសំរាប់កំរាលលើផ្ទៃក្តាររឹង, ជាពិសេសនៅក្នុងបន្ទប់ទឹក
- ជ្រើសចំណូលចិត្តចុងបញ្ចប់ដែលមានអារម្មណ៏ពេញចិត្ត, និងមិនមែនជាមន្ទីរស្ថាប័ន
- ចំណូលចិត្តសំរាប់ម៉ាស៊ីនបោកនិងម៉ាស៊ីនហាល, ឬយ៉ាងហោចណាស់ផ្តល់នូវចំណូលចិត្តចាំបាច់
- ចំណូលចិត្តសំរាប់ម៉ាស៊ីនកំដៅពណ៌សំរាប់ពណ៌ថ្នាំនិងការសង់ផ្ទៃក្នុងចុងបញ្ចប់ផ្សេងទៀត

### កន្លែងទីតាំងសហគមន៍

- បន្ទប់ហាត់ប្រាណ
- បន្ទប់ហាត់រៀនកុំព្យូទ័រ
- មជ្ឈមណ្ឌលសិក្សាមតេយ្យកុមារ
- បន្ទប់សហគមន៏គ្មានភាពព្រួយបារម្ភ មានបន្ទប់ទទួលទាន, មានចង្ក្រានដុតអុស, និងបណ្ណាល័យ
- មន្ទីរសហគមន៏អាចបើកធ្វើការច្រើនម៉ោងដែលស្របតាមគ្រប់តារាងពេល

### ធ្វើការសន្និដ្ឋានផែនការការដ្ឋាន

ក្រុម A
ក្រុម A ចង់បានផ្ទះមានមួយជាន់ ដោយគ្មានជណ្តើរ និងមានផែនការការដ្ឋានមានកន្លែងចំហ ធំទូលាយសំរាប់សួនបន្លែនិងសកម្មភាពក្រៅផ្ទះផ្សេងៗទៀត។.

ក្រុម B
ក្រុម B ចង់បានផែនការការដ្ឋានដែលធ្វើកន្លែងសំរាប់រស់នៅរបៀបឯកជន និងផ្តល់កន្លែងរស់នៅដាច់គ្នា សំរាប់ប្រភេទលំនៅដ្ឋានផ្សេងៗគ្នា ដូចជាលំនៅដ្ឋានសំរាប់មនុស្សចាស់ និងលំនៅដ្ឋានគ្រួសារមានកូន។

ក្រុម C
ក្រុម C រៀបចំការព្រាងផែនការពីរការដ្ឋាន។ ពួកគេចង់ធ្វើប្លង់ដែលផ្តល់ផ្ទះមានកន្លែងប្រជុំនៅខាងក្រៅ និងខាងក្នុង “ជាក្រុម” និងហោណ៍ងដែលធ្វើឲ្យមានអារម្មណ៏រស់នៅជាសហគមន៏។ អ្នកចូលរួមចង់ ឃើញមានផ្ទះជាច្រើនដែលគ្មានជណ្តើរ។



# ប្តូរគំនិតរបស់សហគមន៍ឲ្យទៅជាផែនការធ្វើប្លង់




## ប្លុក 1800

នៅប្លុក 1800, ផ្ទះល្វែង និង ផ្ទះល្វែងដំបូលរាបគឺសង់ផ្តុំនៅជុំវិញមណ្ឌលទីធ្លាដោយមានកន្លែងទស្សនាទៅទិសខាងកើត និងព្រះអាទិត្យពេលព្រឹក។

1. ទីធ្លាមានសួនបន្លែសហគមន៍ដែលមានកន្លែងទទួលទានអាហារក្នុងសួនដោយមានចង្ក្រានអាំងសាច់ និងមានកន្លែងសំរាប់ក្មេងទូទៅលេង
2. កន្លែងចតរថយន្តនៅក្រៅផ្លូវតាមចន្លោះច្រកផ្លូវតទៅរកផ្ទះដោយមានជណ្តើរនិងផ្លូវជម្រាលអាចចេញចូលបាន
3. ផ្លូវថ្នល់មានរន្ធលូតូចៗច្រើនដើម្បីឲ្យបន្ថយទឹកជំនន់កុំឲ្យជន់
4. ផ្ទះល្វែងបែរមុខទៅរកផ្លូវដើម្បីឲ្យស៊ីនឹងមូលដ្ឋាននៅព័ទ្ធជុំវិញ
5. ជណ្តើរឡើងទៅរកផ្លូវអាចទស្សនាទៅមាត់ទឹកនិងភ្នំ
6. មានកន្លែងចតរថយន្តតាមដងផ្លូវបន្ថែមទៀត
7. ដើមអ្នកជាច្រើននឹងរក្សាទុកឲ្យនៅមាន

## ប្លុក 2500

ប្លុក 2500 មានកសាងចំរុះផ្ទះតូចៗ, ផ្ទះល្វែង, ផ្ទះមានកន្លែងចតរថយន្ត, អាគារនិងអាគាររាបច្រើនជាន់។ អាគារទាំងអស់គឺរៀបចំកសាងនៅជុំវិញសួន, ទីធ្លា និងកន្លែងចន្លោះធម្មតា។ គ្រប់ផ្ទះទាំងអស់នឹងមានកន្លែងខាងក្រៅជារបៀបឯកជន ដូចជារានក្រោយផ្ទះ, ហោណាំង, ឬទីធ្លាតូចៗ។

1. សួនបន្លែសហគមន៍
2. កន្លែងចតរថយន្តក្រៅពីថ្នល់
3. ផ្លូវថ្នល់មានរន្ធលូតូចៗច្រើនដើម្បីបន្ថយទឹកជំនន់កុំឲ្យជន់
4. ទីធ្លា G បានធ្វើប្លង់ដើម្បីឲ្យរថយន្តបន្ថយល្បឿន និងលើកទឹកចិត្តដល់អ្នកថ្មើជើង
5. ផ្លូវឆ្លងកាត់តភ្ជាប់ទៅផ្លូវ S Yakima Avenue និង S G Street
6. ទីធ្លាឯកជន
7. សួនបន្លែសហគមន៍លើដំបូល
8. មជ្ឈមណ្ឌលសហគមន៍ និងមជ្ឈមណ្ឌលសិក្សាមតេយ្យកុមារ
9. ទ្វារច្រកចូលថ្មី នៅ Hilltop Neighborhood
10. អាគារជួល
11. ដើមឈើពីមុននឹងរក្សាទុក
12. ជណ្តើរឡើងទៅរកផ្លូវ
13. ធ្វើប្លង់មជ្ឈមណ្ឌលឡើងវិញ ដើម្បីផ្តល់ឲ្យមានសកម្មភាពហាត់ប្រាណច្រើនឡើងថែមទៀត។






ឧទាហរណ៍នៃផ្ទះល្វែងនៅ ប្លុក 2500 ។

# Hillside Terrace
Tacoma Housing Authority

Tacoma Housing Authority
902 S L Street
Tacoma, WA 98405

PRSRT FIRST
CLASS
U.S. POSTAGE
PAID
SEATTLE, WA
PERMIT NO. 1046

## ដើម្បីព័ត៌មានច្រើនថែមទៀត ឬដើម្បីចូលរួម

- មើលតួបព័ត៌មាននៅ 2500 Hillside Terrace Office
- រកមើលសេចក្ដីជូនដំណឹងតាមប៉ុស្ដិ៍សំបុត្រ។
- ចូរទៅមើលគំរោងការក្នុងវិបសៃនៅ http://www.tacomahousing.org
- ចូរទាក់ទងមកយើង:

Steve Clair
នាយកគ្រប់គ្រងគំរោងការថ្នាក់ឯក
អាជ្ញាធរលំនៅដ្ឋានក្រុងតាខូម៉ា
អ៊ីមែល: sclair@tacomahousing.org
ទូរស័ព្ទ: (253) 207-4435